ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
លេខ..១២៣២....បទ.....

គោរពជូន
ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី
និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

កម្មវត្ថុ: របាយការណ៍សកម្មភាពការងារសម្រាប់ ៩ខែ និង លើកទិសដៅត្រីមាសទី៤ ឆ្នាំ២០១៤ របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** មេត្តាជ្រាប នូវសកម្មភាពរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (គ.ប.ជ.អ.ប.ទ) មានដូចតទៅ:

ក-សកម្មភាពជាមួយ នឹង អ.ជ.ប.ជ.អ.

១-ក្រុមប្រឹក្សាគោលនយោបាយ: បានចូលរួមប្រជុំក្រុមការងារបច្ចេកទេស រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ស្តីពីមេរោគអេដស៍ និង ជំងឺអេដស៍ នៅទីស្តីការ អ.ជ.ប.ជ.អ.បាន **១លើក** ។

២-ក្រុមប្រឹក្សាគោលនយោបាយ និងក្រុមប្រឹក្សាបច្ចេកទេស: បានចូលរួមសម័យប្រជុំពេញអង្គលើកទី១ របស់ អ.ជ.ប.ជ.អ. កាលពីថ្ងៃទី១៩ ខែ មិថុនា ឆ្នាំ ២០១៤ ។

៣-បានបញ្ជូនមន្ត្រី២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបច្ចុប្បន្នភាពឧបករណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ ដើម្បីបង្កើនប្រសិទ្ធភាពការអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃជាតិឆ្ពោះទៅសម្រេចបាននូវគោលដៅ**សូន្យបី** កាលពីថ្ងៃ ទី៨ -១០ ខែកក្កដា ឆ្នាំ២០១៤។

ខ-សកម្មភាពផ្ទាល់នៅក្នុងក្រសួង

បានធ្វើបទអន្តរាគមន៍ចូលរួមសន្និបាតប្រចាំ ២០១៣ និង លើកទិសដៅ ឆ្នាំ២០១៤ របស់ក្រសួង ប.ទ នាថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០១៤ ។

គ-សកម្មភាពក្រៅក្រសួង

-ក្រុមប្រឹក្សាគោលនយោបាយបានចូលរួមកម្មវិធីប្រកាសដាក់ឲ្យដំណើរការគម្រោង " **រៀនពីការរស់នៅ-កម្ពុជា**"(Learning about living-Cambodia)ដោយប្រើប្រាស់ លេខទូរស័ព្ទខ្លី៤ខ្ទង់ **១២៩៣** ក្នុងការផ្ញើ និងទទួលសារ ដោយមិនគិតថ្លៃ ជាមួយអ្នកជំនាញនៃមណ្ឌលប្រឹក្សាអង្គការ One World ទាក់ទងនឹងសុខភាព បន្តពូជ ផ្លូវភេទ ការបង្ការមេរោគអេដស៍ រក្សាការសម្ងាត់ មិនមានការរើនិច្ច័យ ប្រកបដោយវិជ្ជាជីវៈ ដែលបានប្រព្រឹត្តទៅនៅ សណ្ឋាគារ Intercontinental នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤។

-បានផ្តល់ការប្រឹក្សាដល់តំណាងអង្គការ One World នៅកម្ពុជាស្តី អំពីការស្វែងរកការសហការបន្ថែមពីបណ្តាប្រតិបត្តិករទូរស័ព្ទចល័តផ្សេងទៀត បន្ទាប់ពីទទួលបានការចូលរួមគាំទ្រពីក្រុមហ៊ុន Cellcard។

ឃ-ទិសដៅសម្រាប់ ត្រីមីទី៤ ឆ្នាំ២០១៤

១-ចូលរួមអន្តរាគម តាមរយៈប្រតិបត្តិករទូគមនាគន៍កម្ពុជា ទៅប្រតិបត្តិករទូរស័ព្ទចល័តទាំងអស់ ក្នុងការសរសេរសារ SMS ខ្លីៗបញ្ជូនទៅកាន់ទូរស័ព្ទដៃ ទាក់ទងការអប់រំអំពីជំងឺអេដស៍ និង អំពីគ្រឿងញៀន តាមសំណើអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នាឱកាសព្រះរាជពិធីបុណ្យ អុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក នាថ្ងៃទី៥-៧ ខែវិច្ឆិកា ២០១៤ និងថ្ងៃទី១ ខែធ្នូ ចំពោះ

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨០៩/៤២៨២៤៦
ទូរសារ (៨៥៥) ២៣-៤២៦៥៤១/៤២៦០០៥/៧២៤៨០៩

ចំពោះជំងឺអេដស៍។

២-ចេញប្រកាសថ្មីអំពីសមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងប្រៃសណីយ៍ និងទូរ គមនាគមន៍ ក្នុងអាណត្តិរាជរដ្ឋាភិបាល នីតិកាលទី៥ ។

៣-រៀបចំគោលនយោបាយ ផែនការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងប.ទ. ។

៤-បន្តការសហការដោយផ្ទាល់ ឬដោយប្រយោលជាមួយដៃគូរអភិវឌ្ឍន៍នានា(តាមលទ្ធភាពដែលអាចទាក់ទងនិងធ្វើបាន) និងជាមួយ អ.ជ.ប.ជ.អ. ក្នុងការស្វែងរកការគាំទ្រ ដើម្បីអាចសម្រេចផែនការឆ្នាំ។

៥-ចាប់បន្តចុះសួរសុខទុក្ខ ដើម្បីបានអប់រំ ណែនាំដល់មន្ត្រីមន្ទីរប.ទ. និង និយោជិកនៃសាខាប្រៃសណីយ៍កម្ពុជា ទូរគមនាគមន៍កម្ពុជា នៅតាមបណ្តាខេត្តដែលពុំទាន់បានធ្វើនៅឡើយនាពេលកន្លងមក។

៦-ធ្វើសំណើទៅប្រតិបត្តិករទូរសព្ទ័ និងក្រុមហ៊ុនអ៊ីនធើណែតទាំងអស់ ដែលស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងប.ទ.បង្កើតឲ្យមានតំណាងនិយោជិកជាបណ្តាញសហការជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងប.ទ. ងាយស្រួលផ្សព្វផ្សាយអប់រំបន្តដល់បុគ្គលិក ព្រោះជាសកម្មភាពពហុវិស័យ។

៧-ប្រជុំការងាររបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ដើម្បីពិនិត្យលើសកម្មភាពអនុវត្តការងារ និងបន្តសម្រាប់ត្រីមាសក៏ដូចជាឆមាសបន្ទាប់ ឲ្យបានសំរេចតាមផែនការរបស់ខ្លួន។

ខ-បញ្ហាប្រឈម:

-រាល់សកម្មភាពការងារប្រយុទ្ធនឹងជំងឺអេដស៍ ទាមទារជាចាំបាច់នូវសម្ភារៈនិងថវិកា ឬការចូលរួម និង គាំទ្រជាអាទិភាព ។

-វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ជាវិស័យដែលអាចជួយចូលរួមទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍តាមរយៈសារអប់រំជាដើម បានទូលំទូលាយ ប៉ុន្តែការចូលរួមសហការពីប្រតិបត្តិករទូរស័ព្ទចល័ត នៅមានកម្រិតនៅឡើយ។

-ការស្រាវជ្រាវស្រង់មន្ត្រីរាជការដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ នៅតែជាបញ្ហាអនុវត្តពុំទាន់បាន ទោះបីមានការយល់ដឹងក៏ដោយ។

គ-សំណូមពរ:

សូម អ.ជ.ប.ជ.អ. បន្តការជួយគាំទ្រ ដល់ផែនការរបស់ គ.ប.ជ.អ.ប.ទ.៖

១-សូមជួយ**ផ្តល់រូបភាពទាក់ទងនឹងការផ្សព្វផ្សាយអប់រំអំពីជំងឺអេដស៍** សម្រាប់ប្រើប្រាស់ក្នុងការបោះពុម្ពតែមប្រឹ (ព្រោះអ.ជ.ប.ជ.អ.អាចយល់ ថាតើត្រូវប្រើរូបអ្វីដែលពាក់ព័ន្ធនឹងការអប់រំអំពីមេរោគអេដស៍/ជំងឺអេដស៍ ឯក្រសួងប.ទ.ជាបច្ចេកទេស ថាតើត្រូវឆ្លៃរូបនោះយ៉ាងណាសម្រាប់បោះពុម្ពតែមប្រឹបានល្អធ្វើឲ្យមានការចាប់អារម្មណ៍!)។

<u>បញ្ជាក់:</u> សូមកុំផ្តល់រូបដដែល ។ ធ្លាប់បានប្រើប្រាស់បោះពុម្ពតែមប្រឹរួចម្តងមកហើយនាពេលកន្លងមក **សូមស្នើរូបថ្មី** ។ ចំពោះការស្វែងរករូបភាពពាក់ព័ន្ធការផ្សព្វផ្សាយអប់រំអំពីជំងឺអេដស៍ អាជ្ញាធរអាចបង្កើតកម្មវិធីប្រកួតប្រជែងក្នុងចំណោមសិស្ស និស្សិត ដោយមានរង្វាន់លើកទឹកចិត្ត សម្រាប់ប្រធានបទប្រភេទរូបភាពពីរបែប: **រូបគូរ និងរូបថត** ។ បើធ្វើដូចនេះបាន រូបនេះអាចយកមកធ្វើផ្ទាំងរូបធំៗផ្សព្វផ្សាយ (Bill Board) ក៏បាន ធ្វើតែមប្រឹក៏បាន។

២-រាល់សារ SMS សូមរក្សាគោលការណ៍គឺខ្លីមសារ ជា **សារខ្លីៗ** ដែលងាយសរសេរ និងបញ្ជូនតាមទូរស័ព្ទចល័ត ងាយយល់សម្រាប់អ្នកទទួល និងបង្កការងាយស្រួលដល់ប្រតិបត្តិករចូលរួមជួយផ្សព្វផ្សាយ ក្នុងឱកាសបុណ្យជាតិ ឬព្រឹត្តិការណ៍សំខាន់ផ្សេងៗ។

៣-ជួយស្វែងរកថវិកា ឬរកដៃគូអភិវឌ្ឍន៍ដែលមានលទ្ធភាពជួយជ្រោមជ្រែង ឧបត្ថម្ភដល់ផែនការសកម្មភាពរបស់គ.ប.ជ.អ.ប.ទ. ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធាន អ.ជ.ប.ជ.អ.** មេត្តាជ្រាបជារបាយការណ៍ និង ជួយពិនិត្យលើសំណូមពរដែលបានលើកឡើងមកនេះតាមការគួរ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធាន អ.ជ.ប.ជ.អ.** មេត្តាទទួលនូវសេចក្តីគោរពដ៏ស្មោះ អំពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៤

រដ្ឋលេខាធិការ

និង ជាប្រធាន គ.ប.ជ.អ.ប.ទ

ខាយ ឃុនហេង

ចម្លងជូន:
-ឯកឧត្តមរដ្ឋមន្ត្រី
" ដើម្បីគោរពជូនជ្រាប "
-នាយកដ្ឋានផែនការហិរញ្ញវត្ថុ
" ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ